ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបើកផ្តល់ប្រាក់ឈ្នួល និងប្រាក់អត្ថប្រយោជន៍ ជូនបងប្អូនកម្មករនិយោជិត នៃក្រុមហ៊ុន គ្លូបិល អឺភែរឹល ថិចថាយ (ខេមបូឌា) មេនូហ្វេកឆឺរីង ភីធីអ៊ី អិលធីឌី

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនដំណឹងដល់បងប្អូនកម្មករនិយោជិតនៃក្រុមហ៊ុន គ្លូបិល អឺភែរឹល ថិចថាយ (ខេមបូឌា) មេនូហ្វេកឆឺរីង ភីធីអ៊ី អិលធីឌី មេត្តាជ្រាបថា ដោយអនុវត្តតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្រសួងនឹងចាប់ផ្តើមបើកផ្តល់ថវិកាបុរេប្រទានរបស់រាជរដ្ឋាភិបាលកម្ពុជាជូនបងប្អូន ចាប់ពីម៉ោង ៩:០០នាទីព្រឹក ថ្ងៃពុធ ទី២៦ ខែតុលា ឆ្នាំ២០២២ តទៅ នៅអគ្គលេខាធិការដ្ឋាន គណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា ដែលមានទីតាំងស្ថិតនៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទៅតាមលេខរៀងនៅក្នុងបញ្ជីដែលក្រុមការងារបានកំណត់។

សូមបងប្អូនកម្មករនិយោជិតយកមកជាមួយនូវឯកសារមួយចំនួនដូចខាងក្រោម៖

១. ប័ណ្ណសម្គាល់ខ្លួនកម្មករនិយោជិត (ច្បាប់ដើម) ឬកិច្ចសន្យាការងារ និងសៀវភៅការងារកម្មករនិយោជិត ឬប័ណ្ណបេឡាជាតិសន្តិសុខសង្គម ឬអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន
២. ប័ណ្ណបើកប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិតម្នាក់ៗ (បើមាន)។

អាស្រ័យហេតុនេះ សូម បងប្អូនកម្មករនិយោជិតទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃសុក្រ ១១ រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២

ទូរស័ព្ទទំនាក់ទំនង៖ ០៩២ ១៤១ ០១១
០១២ ៧៦៥ ៧៥៤